# ជំងឺមហារីកថ្លើម



American Liver Foundation
www.liverfoundation.org
1-800-GO-LIVER

## ហេតុអ្វីបានជាថ្លើមមានសារៈសំខាន់?

ថ្លើមគឺជាសរីរាង្គធំជាងគេទីពីរក្នុងខ្លួនរបស់អ្នក និងបិតនៅខាងក្រោមឆ្អឹងជំនីរខាងស្តាំរបស់អ្នក។ វាមានទំងន់ ប្រហែលបីផោន្ត ហើយមានរាងមូលទ្រវែងដូចហ្វ៊ុតបាល់ ដែលរាបនៅលើចំហៀងម្ខាង។

ថ្លើមបំពេញមុខងារជាច្រើនក្នុងខ្លួនរបស់អ្នក។ វារំលាយអ្វីៗដែលអ្នកបរិភោគ និងផឹក ទៅជាថាមពល និងទៅជា អាហារជីវជាតិ ដែលខ្លួនរបស់អ្នកអាចប្រើ។ ថ្លើមក៏យកសារធាតុពុលចេញពីឈាមរបស់អ្នកដែរ។

## តើរោគមហារីកថ្លើមជាអ្វី?

ជំងឺមហារីកថ្លើមគឺការជាការលូតលាស់ និងការរីករាលដាលនៃកោសិកាមិនល្អនៅក្នុងថ្លើម។ ជំងឺថ្លើមដែលចាប់ផ្តើមកើតនៅក្នុងថ្លើមគឺជាជំងឺថ្លើមបឋម។ ជំងឺមហារីកដែលកើតចេញពីសរីរាង្គដទៃ ហើយរីករាលដាលទៅដល់ថ្លើមគឺជាជំងឺមហារីកកើតថ្មី។

ជារៀងរាល់ឆ្នាំ ប្រជាជនអាមេរិកប្រមាណ21000នាក់ត្រូវបានគេធ្វើរោគវិនិច្ឆ័យរកឃើញថាមានផ្ទុកជំងឺថ្លើមប្រភេទបឋម។ ជំងឺថ្លើមប្រភេទបឋម ជាជំងឺមហារីកមួយក្នុងចំណោមជំងឺមហារីកមួយចំនួន តូចដែលកើនឡើងនៅអាមេរិក។ ជំងឺប្រភេទនេះកើតលើបុរស2ដងច្រើនជាងស្ត្រី។

## តើមូលហេតុអ្វីដែលនាំឲ្យកើតជំងឺថ្លើម?

មានកត្តាគ្រោះថ្នាក់ជាច្រើនដែលនាំឲ្យកើតជំងឺមហារីកថ្លើម

- ជំងឺក្រិនថ្លើម(មានសន្លាកនៅថ្លើម)អាចបណ្តាលឲ្យមានជីងឺមហារីកថ្លើម។ នៅសហរដ្ឋអាមេរិក ជំងឺថ្លើមរ៉ាំរ៉ៃប្រភេទC ដែលបណ្តាលមកពីការទទូលទានគ្រឿងស្រវឹងជាកត្តាគ្រោះថ្នាក់ដែលនាំឲ្យមានជំងឺថ្លើម។
- ការកើតជំងឺថ្លើមប្រភេទBនិងប្រភេទCរយៈពេលយូរអាចបណ្តាលឲ្យមានមហារីកថ្លើមព្រោះថាជំងឺនេះនាំឲ្យមានមហារីកថ្លើម។ ជំងឺថ្លើម នាំឲ្យកើតមានជំងឺមហារីកថ្លើម ដោយមិនមានជំងឺក្រិនថ្លើម។
- ការកើនឡើងជាតិខ្លាញ់ច្រើនពេកក៏អាចនាំឲ្យកើតមានជំងឺមហារីកថ្លើមដែរ។
- ជំងឺទឹកនោមផ្អែមក៏ជាកត្តាបង្កឲ្យមានមហារីកថ្លើមដែរ។

## តើជំងឺមហារីកថ្លើមមានរោគសញ្ញាដូចម្តេច?

ជាទូទៅជំងឺមហារីកថ្លើមមិនបង្ហាញរោគសញ្ញាទេពោលគឺរហូតឈានដល់ដំណាក់កាលធ្ងន់ធ្ងរទើបវាលេចចេញរោគសញ្ញា។ រោគសញ្ញាទាំងនោះរួមមាន៖ អការៈអស់កម្លាំងល្ហិតល្ហៃ ហើមពោះ ឈឺចាប់នៅម្តុំផ្នែកខាងលើនៃពោះ ឈឺខ្នងឈឺចង្កេះ ក្អួតចង្អោរ បាយមិនបាន មិនមាន អារម្មណ៍ចង់ញ៉ាំអាហារ ស្រកទម្ងន់ ខ្សោយកម្លាំង ឡើងកំដៅ ខាន់លឿង (ស្បែកនិងភ្នែកឡើងលឿង) ។

## តើគេអាចធ្វើរោគវិនិច្ឆ័យជំងឺមហារីកថ្លើមដោយវិធីណា?

គេអាចធ្វើរោគវិនិច្ឆ័យជំងឺមហារីកថ្លើមដោយការពិនិត្យលើរាងកាយនិងការធ្វើតេស្តដោយប្រើរូបភាព។ ដើម្បីរកឲ្យឃើញរោគសញ្ញានៃជំងឺមហារីកថ្លើម វេជ្ជបណ្ឌិតអាចនឹងធ្វើការពិនិត្យឈាម ពិនិត្យមើលរលកសញ្ញាអ៊ុលត្រាសោន ការស្កេនដោយកាំរស្មីX (CT) ការធ្វើតេស្តដោយប្រើរូបភាពរំញ័រ នៃមេដែក(MRI) និងការថតសរសៃឈាមផ្ទាល់តែម្តង។ វេជ្ជបណ្ឌិតរបស់អ្នកអាចធ្វើការកាត់យកសំណាកថ្លើមដើម្បីយកទៅពិនិត្យក្នុងមីក្រូទស្សន៍។ អំឡុងពេលកាត់សំណាកជាលិកាថ្លើមមួយផ្នែកតូចត្រូវបានកាត់ចេញដើម្បីយកទៅពិនិត្យក្នុងមន្ទីរពិសោធន៍។

## តើជំងឺមហារីកថ្លើមអាចព្យាបាលតាមវិធីណា?

ការព្យាបាលជំងឺមហារីកថ្លើមផ្អែកទៅលើ:

- ល័ក្ខខ័ណ្ឌរបស់ថ្លើម
- ទំហំ ទីតាំង និងចំនួនដុំសាច់
- ប្រសិនបើជំងឺមហារីករីករាលដាលនៅក្រៅថ្លើម
- អាយុ និងសុខភាពរបស់អ្នកជំងឺ

ជំរើសព្យាបាល ប្រសិនបើមហារីកមិនទាន់រីករាលដាល ហើយសាច់ផ្សេងទៀតនៃថ្លើមនៅល្អនៅឡើយ

**វិធីបណ្តុះ**

សម្រាប់អ្នកជំងឺមួយចំនួន ប្រសិនបើមហារីកមិនទាន់រាលដាលទេ វិធីបណ្តុះគឺជាជំរើសដ៏ល្អមួយ។

**វិធីវះកាត់**

ប្រសិនបើមហារីកត្រូវបានរកឃើញពីដំណាក់កាលដំបូងហើយផ្នែកដទៃនៃសាច់ថ្លើមនៅល្អវេជ្ជបណ្ឌិតអាចធ្វើការវះកាត់យកសាច់មហារីកចេញ
វិធីនេះហៅថាវិធីកាត់ជាលិកាថ្លើមមួយផ្នែក (partial hepatectomy)

**វិធីបាញ់កាំរស្មី**

វិធីនេះប្រើប្រដាប់ស្ទង់លោហៈ ដើម្បីបង្កក និងបំផ្លាញកោសិកាមហារីក។

**វិធីចាក់បញ្ចូលអេតាណុល**

វិធីនេះគេចាក់បញ្ចូលអាកុលទៅក្នុងសាច់ដុះនៅថ្លើម ដើម្បីបំផ្លាញកោសិកាមហារីក។

**វីធីគីមី**

វិធីនេះគេប្រើថ្នាំដើម្បីបំផ្លាញកោសិកាមហារីក។ ក្នុងករណីខ្លះ វិធីនេះគេបាញ់សារធាតុគីមីបញ្ចូលទៅក្នុងដុំសាច់ដែលដុះនៅថ្លើមតែម្តង។

**វិធីព្យាបាលដោយវិទ្យុសកម្ម**

វិធីនេះគេប្រើកាំរស្មីXបាញ់កំទេចកោសិកាមហារីក។

**វិធីព្យាបាលដោយប្រើឱសថ Sorafenib**

Sorafenibគឺជាឱសថសម្រាប់លេបដែលត្រូវបានអនុម័តឲ្យប្រើប្រាស់ដោយស្ថាបនFDA សម្រាប់ប្រើប្រាស់ជាមុន
ក្នុងករណីមានសាច់ដុំដំបៅមហារីកចេញពីកោសិកាថ្លើម (ប្រភេទសាមញ្ញបំផុតនៃជំងឺមហារីកថ្លើម)។

## តើមធ្យោបាយល្អបំផុតដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃជំងឺមហារីកថ្លើមជាអ្វី?

វិធានការដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃជំងឺមហារីកថ្លើមមាន៖

- ជួបជាមួយវេជ្ជបណ្ឌិតជំនាញខាងជំងឺមហារីកថ្លើមជាប្រចាំ។
- សុំយោបល់ពីវេជ្ជបណ្ឌិតរបស់លោកអ្នកអំពីវិធីការពាររោគថ្លើមរួមមាន ការចាក់វ៉ាក់សាំងមេរោគថ្លើមប្រភេទA និងប្រភេទB។
- ចាត់វិធានការការពារឆ្លងប្រភេទB និងប្រភេទC។
- ប្រសិនបើកើតជំងឺថ្លើមរួចហើយ ត្រូវធ្វើតាមការណែនាំរបស់វេជ្ជបណ្ឌិតរបស់អ្នកដើម្បីទទួលការព្យាបាល និងតាមដាមការវិវឌ្ឍន៍របស់ជំងឺជាប្រចាំ។
- ប្រសិនបើអ្នកមានរោគធាត់ជ្រុល ទឹកនោមផ្អែម ឬទទួលទានគ្រឿងស្រវឹងច្រើនពេក អ្នកត្រូវសុំយោបល់ពីវេជ្ជបណ្ឌិតអំពីសុខភាពថ្លើម និងការតាមដានការវិវឌ្ឍន៍នៃជំងឺមហារីក។

## សេចក្តីសង្ខេប

- មហារីកថ្លើមគឺជាការរីកលូតលាស់ និងការរាលដាលនៃជាលិកាថ្លើមខ្សោយ។
- មហារីកដែលចាប់ផ្តើមកើតក្នុងថ្លើមជាមហារីកថ្លើមបឋម។ មហារីកដែលរាលដាលពីថ្លើមទៅសរីរាង្គដទៃទៀត គឺជាមហារីកថ្លើមប្រភេទថ្មីឈ្មោះ metastatic liver cancer។
- ប្រជាជនអាមេរិកប្រមាណ21000នាក់ត្រូវគេធ្វើរោគវិនិច្ឆ័យឃើញមានមហារីកថ្លើមបឋម។
- មហារីកថ្លើមប្រភេទបឋមជាមហារីកមួយប្រភេទក្នុងចំណោមជំងឺមហារីកដែលកើនឡើងនៅអាមេរិក។
- មហារីកថ្លើមបឋមនេះកើតលើមនុស្សប្រុស2ដងច្រើនជាងមនុស្សស្រី។
- កត្តាគ្រោះថ្នាក់នៃជំងឺមហារីកបឋមគឺបណ្តាលឲ្យកើតជំងឺថ្លើមដទៃទៀត ដូចជាជំងឺក្រិនថ្លើម ជំងឺថ្លើមប្រភេទ B និងប្រភេទ C។
- ជាទូទៅជំងឺមហារីកថ្លើមមិនមានរោគសញ្ញាទេ។
- វេជ្ជបណ្ឌិតតែងតែឲ្យយោបល់ទៅអ្នកជំងឺដែលប្រឈមនឹងគ្រោះថ្នាក់ខ្លាំងដោយសារជំងឺមហារីកថ្លើមឲ្យតាមដានការវិវឌ្ឍន៍នៃមេរោគថ្លើមជាប្រចាំ។
- ជំងឺមហារីកថ្លើមត្រូវបានគេរកឃើញតាមរយៈការធ្វើរោគវិនិច្ឆ័យលើរាង្គកាយ និងការធ្វើតេស្តរូបភាព។
- ការព្យាបាលមេរោគថ្លើមពឹងផ្អែកទៅលើល័ក្ខខ័ណ្ឌថ្លើម ទំហំ ទីតាំង និងចំនួនដុំសាច់ ព្រមទាំងអាយុ និងសុខភាពរបស់អ្នកជំងឺ ប្រសិនបើមហារីករាលដាលចេញពីថ្លើម។

American Liver Foundation
www.liverfoundation.org

**1-800-GO-LIVER**

កូនសៀវភៅផ្សព្វផ្សាយនេះអាចបោះពុម្ពបានដោយសារជំនួយដ៏សប្បុរសពីក្រុមហ៊ុនចែកចាយឱសថ Bayer Healthcare និង ក្រុមហ៊ុនចែកចាយឱសថ Onyx

©2009 American Liver Foundation. All rights reserved.